ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

លេខ ២៧៤៣ ព.ណ....ស.ហ.អ.

ភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**
**ឯកឧត្តមនាយកសាលាតុលាការជាន់ខ្ពស់**

កម្មវត្ថុ: សំណើសុំចាត់បញ្ជូនមន្ត្រីទំនាក់ទំនង (Liaison Officer) មកចូលរួម កិច្ចប្រជុំស្តីពីការតម្រង់ទិសរបស់គម្រោងពង្រឹងក្របខ័ណ្ឌសមាហរណកម្មពាណិជ្ជកម្ម " Orientation Meeting on Enhanced Integrated Framework [EIF Tier1]" ។

ភ្ជាប់ជូន: បញ្ជីរាយនាមរបស់មន្ត្រីទំនាក់ទំនង និង របៀបវារៈនៃកិច្ចប្រជុំ ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា៖ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងពាណិជ្ជកម្ម នឹងរៀបចំកិច្ចប្រជុំមួយ ស្តីពីការតម្រង់ទិសរបស់គម្រោងពង្រឹងក្របខ័ណ្ឌសមាហរណកម្មពាណិជ្ជកម្ម " Orientation Meeting on Enhanced Integrated Framework [EIF Tier1]" ដល់មន្ត្រីទំនាក់ទំនង (Liaison Officer) ក្នុងគោលបំណងផ្សព្វផ្សាយ និងតម្រង់ទិសនៃដំណើរការអនុវត្តរបស់គម្រោង EIF Tier1 ដើម្បីអោយភ្នាក់ងារដែលពាក់ព័ន្ធបានយល់ដឹង និងមានភាពងាយស្រួលក្នុងការចូលរួមអនុវត្តន៍ ។ ជាមួយគ្នានេះដែរ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនឹងពិនិត្យលទ្ធភាព ក្នុងការផ្តល់សំភារៈការិយាល័យដល់មន្ត្រីទំនាក់ទំនងសម្រាប់បម្រើការងារនៅក្នុងនាយកដ្ឋានរបស់ខ្លួន ដើម្បីជួយជម្រុញក្នុងការអនុវត្តគម្រោង ។ កិច្ចប្រជុំនេះនឹងប្រព្រឹត្តទៅនៅ ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ ព្រឹក នៅក្រសួងពាណិជ្ជកម្ម ក្រោមអធិបតីភាពរបស់ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋលេខាធិការ និងជា EIF Focal Point ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាចាត់បញ្ជូនមន្ត្រីទំនាក់ទំនង (Liaison Officer) មកចូលរួមកិច្ចប្រជុំខាងលើដោយក្តីអនុគ្រោះ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋលេខាធិការ

ចែម_សុខណៃ

ចម្លងជូន៖
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តម ប៉ាន សូរស័ក្តិ
- ឯកឧត្តម សុខ សុភ័ក្ត្រ
- ឯកសារកាលប្បវត្តិ